តមកពីទំព័រទី១ "ឃ"

សណ្ឋាកាឡឺរ៉ូយ៉ាល់នោះបាន ប្រកាសនូវរបាយការណ៍ស្តីពី សវនកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោត និងការផ្តល់អនុសាសន៍ ដល់គ.ជ.ប ក៏ដូចជារដ្ឋាភិបាល *ហ៊ុន សែន* ឱ្យយកចិត្តទុកដាក់ជាអាទិភាពទៅលើប្រជាពលរដ្ឋខ្មែរ ដែលមិនទាន់ចុះឈ្មោះបោះឆ្នោត ។

យោងតាមសវនកម្មរបស់អង្គការក្រៅរដ្ឋាភិបាលទាំង៤ ដែលគួរឱ្យជឿទុកចិត្តបានលើបញ្ជីឈ្មោះអ្នកបោះឆ្នោតបង្ហាញថា ប្រជាពលរដ្ឋ៨៨.៨%នៃមានសិទ្ធិបោះឆ្នោតទាំងអស់បានចុះឈ្មោះ ។ ប៉ុន្តែមានប្រជាពលរដ្ឋចំនួន១១.២%នៅមិនទាន់បានចុះឈ្មោះនៅឡើយ ដែលតួលេខនេះបានបញ្ជាក់នូវការប៉ាន់ប្រមាណរបស់គ.ជ.ប ពីអ្នកមានសិទ្ធិបោះឆ្នោតចំនួន៦៨២០០០នាក់ ដែលចាំបាច់ត្រូវចុះឈ្មោះនោះពិតជាត្រឹមត្រូវ ។

លោក *ហង្ស ពុទ្ធា* នាយកប្រតិបត្តិអង្គការនិចហ្វិកបាននិយាយថា យោងតាមលទ្ធផលនៃការស្រាវជ្រាវបានឱ្យដឹងថា ការចុះឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតវាមានសារៈសំខាន់ខ្លាំងជាងការសំអាតបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅថ្ងៃទី១៥កញ្ញា ដល់ថ្ងៃទី២០តុលា ឆ្នាំ២០០៧ ។

លោក *ហង្ស ពុទ្ធា* បានបន្តទៀតថាវាគឺជាអាទិភាពចាំបាច់បំផុតរបស់គ.ជ.បសម្រាប់ខែក្រោយ បើសិនជាគ.ជ.បលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីសម្រាប់ដំណើរការចុះឈ្មោះបោះឆ្នោត វាចាំបាច់ទាមទារឱ្យមានការផ្តល់នូវភស្តុតាងច្បាស់លាស់ថា ទិន្នន័យលើបញ្ជីឈ្មោះ វាមិនត្រឹមត្រូវ ។

សវនកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោត ឬត្រួតពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត គឺជាការវាយតម្លៃមួយ ដែលមានគុណភាពជាលក្ខណៈប្រព័ន្ធ និងវិទ្យាសាស្ត្រនៃបញ្ជីអ្នកបោះឆ្នោត ហើយបានរៀបចំឡើងកាលពីថ្ងៃទី១០-១៤សីហា ឆ្នាំ២០០៧ ដោយមានកិច្ចសហការរវាងអង្គការនិចហ្វិក, ខុមហ្វ្រែល ក្រោមជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងNDI ។

លោក *ហង្ស ពុទ្ធា* បានឱ្យដឹងទៀតថា អ្នកស្ម័គ្រចិត្តរបស់អង្គការទាំងពីរនេះបានបំពេញការងារនៅតាមឃុំ-សង្កាត់ចំនួន៣៨០ទូទាំងប្រទេស ហើយបានសម្ភាសន៍អ្នកមានសិទ្ធិបោះឆ្នោតចំនួន៣៧៩៦នាក់ ។ ហើយការធ្វើតេស្តមានពីររបៀប គឺ -តេស្តពីបញ្ជីទៅមនុស្ស គឺធ្វើឡើងដោយអ្នកសង្កេតការណ៍ធ្វើការជ្រើសរើសយកឈ្មោះពីបញ្ជីចុះឈ្មោះបោះឆ្នោតមកតាមបែបស្ថិតិ ហើយបន្ទាប់មកធ្វើការទំនាក់ទំនងទៅកាន់អ្នកបោះឆ្នោតដើម្បីសាកសួរពីពត៌មានដ៏ត្រឹមត្រូវរបស់គាត់ ។

-ចំណែកឯតេស្តពីមនុស្សទៅបញ្ជីគឺជ្រើសរើសអ្នក ដែលមានសិទ្ធិបោះឆ្នោតនៅកន្លែងផ្សេងៗគ្នាពីសហគមន៍ ហើយមានពត៌មានទាក់ទងនឹងការចុះឈ្មោះឆ្នោតនឹងត្រូវធ្វើការត្រួតពិនិត្យធៀបនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោត ។

លោក *ហង្ស ពុទ្ធា* បានពន្យល់ថា ផ្តើមចេញពីការធ្វើតេស្តពីបញ្ជីទៅមនុស្សជាង៣/៤នៃបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលស្មើ៧៧.៣% គឺមានលក្ខណៈត្រឹមត្រូវ ។ ចំនួនដល់ទៅ១០.៥ភាគរយជាចំនួននៃអ្នកបោះឆ្នោត ដែលនឹងអាចផ្លាស់ទីលំនៅជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្ន ។

ប៉ុន្តែបើតាមការរួមបញ្ចូលទាំងពីរតេស្តខាងលើនោះបង្ហាញថា បញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលមានឈ្មោះអ្នកបោះឆ្នោតត្រឹមត្រូវមានចំនួន៨៦.២ភាគរយ ហើយ៨៨.១

ភាគរយ សម្រាប់អាសយដ្ឋានដែលត្រឹមត្រូវ ។

លទ្ធផលបង្ហាញថា អ្នកបោះឆ្នោត ដែលប្រើប្រាស់អត្តសញ្ញាណប័ណ្ណដើម្បីយកទៅចុះឈ្មោះឆ្នោតមានចំនួន៧៦.៥% ចំណែកឯអ្នកបោះឆ្នោតមានអាយុក្រោម១៩ឆ្នាំ ដែលប្រើអត្តសញ្ញាណប័ណ្ណយកទៅចុះឈ្មោះបោះឆ្នោតមានចំនួនតែ៥៦.៥%ប៉ុណ្ណោះ ។

លោក *មា សុផល* អ្នកសម្របសម្រួលកម្មវិធីត្រួតពិនិត្យនៃការបោះឆ្នោតមកពីអង្គការខុមហ្វ្រែលបានពន្យល់ថា អត្តសញ្ញាណប័ណ្ណមានបិទរូបថតអាចបញ្ជាក់ពីអត្តសញ្ញាណពិតប្រាកដអ្នកបោះឆ្នោតបាន ។ ដូច្នេះការបញ្ជប់ការចែកអត្តសញ្ញាណប័ណ្ណនឹងមិនត្រឹមតែអាចប្រើដើម្បីជួយសម្រួលដល់ការចុះបញ្ជីឈ្មោះបោះឆ្នោតបានតែប៉ុណ្ណោះទេ វាថែមទាំងអាចជួយកាត់បន្ថយនូវភាពមិនប្រក្រតីបានច្រើនផងដែរ ។

របាយការណ៍ដែលចែកឱ្យក្រុមអ្នកកាសែតបានបង្ហាញថា ចំនួនបុរសហាក់បីដូចជាមិនបានចុះឈ្មោះបោះឆ្នោតច្រើនជាងស្ត្រីតាមរយៈកម្រិត៣.២% ។ លើសពីនេះទៀត អ្នកបោះឆ្នោតថ្មី ដែលមានអាយុក្រោម១៩ឆ្នាំ មានចំនួន១២% ដែលវាហាក់ដូចជាបានចុះឈ្មោះតិចជាងអ្នកបោះឆ្នោត ដែលមានអាយុលើសពី១៩ឆ្នាំ ។ ដំណើរការនៃការចុះឈ្មោះបោះឆ្នោតអាចនឹងត្រូវមានប្រសិទ្ធភាពជាង បើសិនជាយកចិត្តទុកដាក់ទៅលើអ្នកបោះឆ្នោត ដែលគ្រប់អាយុ និងអ្នកបោះឆ្នោតជាបុរស ។

របាយការណ៍ដដែលសរសេរថា ប្រភពពតិមានចំបង ដែលគេឧស្សាហ៍យកមកប្រើជាងគេសម្រាប់ការចុះឈ្មោះបោះឆ្នោតគឺ មេភូមិចំនួន៤៣.៨% ជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗមានចំនួន៣៤.៥% ។

មជ្ឈដ្ឋាននានាទាមទារឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គិតគូរឡើងវិញអំពីការចុះឈ្មោះរបស់ប្រជាពលរដ្ឋ ដើម្បីធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋបានចូលរួមបោះឆ្នោតបានគ្រប់ៗគ្នា ទើបការបោះឆ្នោតនាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ខាងមុខអាចប្រព្រឹត្តទៅ ដោយត្រឹមត្រូវនិងយុត្តិធម៌ពិតប្រាកដ៕

Article: Samleng Yuvachon Khmer (09/07/07)

**Title: NGOs Continuously Pays Attention on the Voter Registration**

**(The rest of the article is the same as NDI Press Release on September 6, 2007)**